ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ០១២/១៥ ប.ស.ស

# សេចក្តីណែនាំ

## ស្តីពីការប្រើប្រាស់សារអេឡិចត្រូនិច ប.ស.ស

ក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះប្រព័ន្ធសារអេឡិចត្រូនិចនៃ ប.ស.ស មានការរអាក់រអួលក្នុងការផ្ញើទៅកាន់Domainខាងក្រៅមួយចំនួន(Yahoo, Gmail,...) ដោយសារមានការឆ្លងមេរោគ Spam។ បន្ទាប់ពីការិយាល័យព័ត៌មានវិទ្យាបានដោះស្រាយបញ្ហាខាងលើការផ្ញើសារទៅកាន់ Domain ខាងក្រៅបានដំណើរការជាធម្មតាឡើងវិញ។

ដើម្បីធានាឲ្យបាននូវសុវត្ថិភាព និងឲ្យមានប្រសិទ្ធិភាពខ្ពស់បន្ថែមទៀត នៅក្នុងការប្រើប្រាស់ប្រព័ន្ធសារអេឡិចត្រូនិច ប.ស.ស ខ្ញុំសូមណែនាំចំពោះ លោក-លោកស្រី មន្ត្រីរាជការ បុគ្គលិក នៃ ប.ស.ស ដូចតទៅ៖

១.សូមកុំយកសារអេឡិចត្រូនិច ប.ស.ស ក្នុងការចុះឈ្មោះប្រើប្រាស់នៅលើគេហទំព័រផ្សេងៗ ដូចជាគេហទំព័រ Facebook Twitter ។ល។

២.សូមកុំចុចលើតំណភ្ជាប់(Link) និងកុំឆ្លើយតប(Reply) ជាមួយនឹងសារអេឡិចត្រូនិចផ្សេងៗ ដែលលោក-លោកស្រី មិនស្គាល់ប្រភពច្បាស់លាស់

៣.សូមធ្វើការលុបចោលជាប្រចាំនូវសារអេឡិចត្រូនិចចាស់ៗដែលពុំចាំបាច់ ដើម្បីកុំឲ្យទំហំនៃ Mailbox លើសពីចំនួន០២GB ដែលធ្វើអោយ លោក-លោកស្រី មិនអាចផ្ញើសារចេញ-ចូលបាន

៤.នៅពេលមន្ត្រី-បុគ្គលិក ផ្ទេរចេញ ឬឈប់ពីការងារ សូមប្រធានការិយាល័យសាមី ធ្វើលិខិតមកការិយាល័យព័ត៌មានវិទ្យា ដើម្បីលុបឈ្មោះចេញពីការប្រើប្រាស់ប្រព័ន្ធសារអេឡិចត្រូនិច ប.ស.ស

៥.ក្នុងករណីមានការសង្ស័យថា កុំព្យូទ័ររបស់លោក-លោកស្រីមានការឆ្លងមេរោគ Spam សូមលោក-លោកស្រីធ្វើទំនាក់ទំនងមកមន្ត្រី-បុគ្គលិក នៃការិយាល័យព័ត៌មានវិទ្យា ដែលទទួលបន្ទុកការិយាល័យ និងការិយាល័យសាខាខេត្ត-ខណ្ឌ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រី មន្ត្រីរាជការ បុគ្គលិក នៃ ប.ស.ស ទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តន៍នូវសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធិភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥

នាយក

អ៊ុក-សមវិទ្យា